ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៧ សហវ.ប្រក

# សារាចរណែនាំ

## ស្តីពី

## ការគ្រប់គ្រងប្រមូលពន្ធលើប្រាក់ចំណេញ និងពន្ធផ្សេងៗទៀត របស់សហគ្រាសធានារ៉ាប់រង

កន្លងមក អនុលោមតាមមាត្រា ២១នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ចំពោះសហគ្រាសធានារ៉ាប់រងឱ្យបានច្បាស់លាស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីពន្ធលើប្រាក់ចំណេញ និងពន្ធលើប្រាក់បៀវត្ស របស់សហគ្រាសធានារ៉ាប់រង ។

ដើម្បីបញ្ជាក់ពីកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសធានារ៉ាប់រងឱ្យបានជាក់លាក់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំបន្ថែមស្តីពីកាតព្វកិច្ចពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្ស និងពន្ធដទៃទៀត របស់សហគ្រាសធានារ៉ាប់រង ដូចខាងក្រោមនេះ :

**១. អំពីពន្ធលើប្រាក់ចំណេញ :**

ពន្ធលើប្រាក់ចំណេញចំពោះសហគ្រាសដែលមានសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ត្រូវបានកំណត់ដូចតទៅ :

ក. ៥ ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត នូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា ។ បុព្វលាភធានារ៉ាប់រងដុលដែលទទួលបាន គឺជាចំនួនទឹកប្រាក់ដែលបានបង់ដោយអ្នកត្រូវបានធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ទោះជាមានលក្ខណៈបង់ទាំងស្រុង ឬបង់រំលស់ទៅតាមដំណាក់កាលក៏ដោយ ដោយផ្អែកលើគោលការណ៍សាច់ប្រាក់

ខ. ចំពោះប្រាក់ចំណូលពីសកម្មភាពដទៃទៀតដែលមិនមែនជាការធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ត្រូវបង់ពន្ធលើប្រាក់ចំណេញ តាមអត្រាពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ

គ. ចំពោះចំណូលការប្រាក់បានមកពីការតំកល់ប្រាក់នៅធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុក ដែលត្រូវបានកាត់ទុក និងបង់ពន្ធរួចហើយ មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញទៀតទេ ។ ប៉ុន្តែត្រូវជាប់ពន្ធកាត់ទុក ដូចបញ្ជាក់នៅចំណុច ទី៣ : អំពីពន្ធកាត់ទុក ខាងក្រោម

ឃ. ប្រាក់ចំណូលផ្សេងៗទៀត ក្រៅពីចំណូលការប្រាក់ដូចមានចែងក្នុងចំណុច (គ) ខាងលើ ត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ ដោយអនុញ្ញាតឱ្យកាត់កងតែចំណាយណាដែលពាក់ព័ន្ធផ្ទាល់ទៅនឹងប្រតិបត្តិការចំណូលផ្សេងៗនោះតែប៉ុណ្ណោះ ។

**២. អំពីប្រាក់រំដោះពន្ធលើប្រាក់ចំណេញ :**

សហគ្រាសធានារ៉ាប់រង ត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញជារៀងរាល់ខែ ចំពោះប្រាក់ចំណូលពីសកម្មភាពដទៃទៀតដែលមិនមែនជាការធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត តាមអត្រា ១ ភាគរយ នៃផលរបរគិតរួមបញ្ចូលទាំងពន្ធ-អាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ដូចមានចែងក្នុងមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ ។

ចំពោះប្រាក់បុព្វលាភធានារ៉ាប់រងដុល ត្រូវបង់តាមអត្រា ៥ ភាគរយ នៃទឹកប្រាក់ដែលទទួលបានក្នុងខែណាមួយ ត្រូវដល់កំណត់ និងត្រូវបង់ក្នុងអំឡុងពេល ១៥ថ្ងៃ នៃខែបន្ទាប់ ។

**៣. អំពីពន្ធកាត់ទុក :**

ចំពោះពន្ធកាត់ទុកត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២៥ថ្មី និង ២៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដូចមានខាងក្រោម :

១. សហគ្រាសធានារ៉ាប់រង ដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោមលើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ :

ក. អត្រា ១៥ ភាគរយ ចំពោះ :

- ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបី... ហើយនឹងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន

ខ. អត្រា ១០ ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលន ឬអចលនទ្រព្យ

គ. អត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់

ឃ. អត្រា ៤ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីសន្សំគ្មានកាលកំណត់ ។

២. សហគ្រាសធានារ៉ាប់រងដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលខាងក្រោមនេះឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធចំនួន ១៤ ភាគរយ នៃទឹកប្រាក់ត្រូវបើក :

ក. ការប្រាក់

ខ. សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ. ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា

ឃ. ភាគលាភ ។

សហគ្រាសធានារ៉ាប់រងបន្តនៅក្នុងប្រទេសកម្ពុជា ដែលបានធ្វើការទូទាត់ប្រាក់ធានារ៉ាប់រងបន្តដែលជាប្រាក់ចំណូលប្រភពកម្ពុជាឱ្យទៅបុគ្គលអនិវាសនជន ពុំមានកាតព្វកិច្ចបង់ពន្ធកាត់ទុកទេ ។

គ្រប់សហគ្រាសត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ ដែលបានកាត់ទុកក្នុងរយៈពេល ១៥ថ្ងៃក្រោយដំណាច់ខែដែលមានការកាត់ទុក ។ សំរាប់គោលដៅនៃពន្ធកាត់ទុក ចំណាយណាមួយដែលជាកម្មវត្ថុនៃពន្ធកាត់ទុក ដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យត្រូវចាត់ទុកថាបានទូទាត់ ។

## ៤. អំពីពន្ធលើប្រាក់បៀវត្ស :

ចំពោះពន្ធលើប្រាក់បៀវត្ស ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី២ (បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស) នៃច្បាប់ស្តីពីសារពើពន្ធ និងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្សលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ។

រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស ។ រូបវន្តបុគ្គលអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា ។ សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកតាមអត្រាកំណើនតាមថ្នាក់ពី ៥ ទៅ ២០ ភាគរយ ។ សម្រាប់និយោជិតអនិវាសនជន ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ទុកតាមអត្រា ២០ ភាគរយនៃទឹកប្រាក់ត្រូវបើកឱ្យមុនការកាត់ទុក ។

## ៥. អំពីពន្ធប៉ាតង់ និងពន្ធដទៃទៀត :

ចំពោះពន្ធប៉ាតង់ ត្រូវបង់ជារៀងរាល់ឆ្នាំលើគ្រប់សកម្មភាពអាជីវកម្ម ហើយត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធនេះ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា រៀងរាល់ឆ្នាំ ។ ប័ណ្ណប៉ាតង់ត្រូវដាក់តាំង ឬព្យួរនៅគ្រឹះស្ថានអាជីវកម្មជាគោលដើម ។

ចំពោះពន្ធអាករដទៃទៀតត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ជាធរមាន ។

សារាចរណែនាំទាំងឡាយណាដែលផ្ទុយពីសារាចរណែនាំនេះ ត្រូវចាត់ទុកជានិរាករណ៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អគ្គលេខាធិការ នាយកខុទ្ទកាល័យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋាននានា និងប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវណែនាំ និងអនុវត្តសារាចរនេះ ឱ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**ចម្លងជូន** :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ